**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ...០៣.....អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលផ្ទៃប្រព័ន្ធបឹងវាលសំណាបទំហំ ៤ ៨១៥ ហិកតា ស្ថិតក្នុងខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៦ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការកំណត់ផ្ទៃប្រព័ន្ធបឹងវាលសំណាប ទំហំ ៤ ៨១៥ ហិកតា ស្ថិតក្នុងខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៣៣ អនក្រ.បក ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១៩ ស្តីពីការកែសម្រួលផ្ទៃប្រព័ន្ធបឹងវាលសំណាប ទំហំ ៤ ៨១៥ ហិកតា ស្ថិតក្នុងខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

ត្រូវបានកាត់ផ្ទៃដីទំហំ ១៣៧ ហិកតា ៨៧ អា និង ៦០ សង់ទីអា (មួយរយសាមសិបប្រាំពីរហិកតា ប៉ែតសិបប្រាំពីរអា និងហុកសិបសង់ទីអា) ស្ថិតនៅឃុំព្រែកអំពិល និងឃុំព្រែកលួង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការកំណត់ផ្ទៃប្រព័ន្ធ

បឹងវាលសំណាប ទំហំ ៤ ៨១៥ ហិកតា ស្ថិតក្នុងខេត្តកណ្ដាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ។

**មាត្រា២ .-**

ត្រូវបានប្រគល់ដីទំហំ ១៣៧ ហិកតា ៨៧ អា និង ៦០ សង់ទីអា (មួយរយសាមសិបប្រាំពីរហិកតា ប៉ែតសិបប្រាំពីរអា និងហុកសិបសង់ទីអា) ស្ថិតនៅស្ថិតនៅឃុំព្រែកអំពិល និងឃុំព្រែកលួង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ជូនឈ្មោះ **ជា ហ៊ុយ** និងឈ្មោះ **ឆ ចេង** ដែលជាម្ចាស់ដីដើមគ្រប់គ្រងជាកម្មសិទ្ធិវិញ។

**មាត្រា៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកណ្ដាលត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៨ រោច ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ